Ottawa County Health Department

# រោគថ្លើមប្រភេទ B [HEPATITIS B]

**តើរោគថ្លើមប្រភេទ B គឺជាអ្វី?**

រោគថ្លើមប្រភេទ B គឺជាជម្ងឺមួយ បង្កដោយវិរុស ដែលប៉ះពាល់ដល់ថ្លើម ។ អ្នកភាគច្រើនជាជម្ងឺទាំងស្រុង ប៉ុន្តែអ្នកជម្ងឺចំនួន 5-10% នឹងក្លាយជាអ្នកមានវិរុសរ៉ាំរ៉ៃ ។

**តើរោគថ្លើមប្រភេទ B ត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?**

រោគថ្លើមប្រភេទ B អាចឆ្លងតាមរយៈវិធីទាំងឡាយខាងក្រោមនេះ:

- ប៉ះឈាម ឬទឹកមកពីខ្លួនអ្នកមានមេរោគនេះ ។
- ពីម្ដាយដែលមានជម្ងឺ ទៅទារកទើបតែកើត នៅក្នុងពេលសំរាលកូន ។
- សាក់រូបលើស្បែក
- បញ្ចូលឈាម
- រួមរ័កដោយមិនការពារ (មិនពាក់ស្រោមអនាម័យ)
- ចែកម្ជុលគ្នា

**តើអាចមានរោគសញ្ញាអ្វីខ្លះ?**

រោគសញ្ញាអាចមានរួមទាំង:

- ភ្នែក ឬស្បែកពណ៌លឿង
- អារម្មណ៍មិនចង់បរិភោគ
- អារម្មណ៍ចង់ក្អួត
- ក្អួត
- ឈឺក្រពះ
- នឿយហត់យ៉ាងខ្លាំង
- អ្នកខ្លះមិនមានរោគសញ្ញាទេ ហើយមិនដឹងខ្លួនថាកំពុងមានមេរោគវិរុសក្នុងខ្លួន

**តើរោគថ្លើមប្រភេទ B ត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្ដេច?**

រោគថ្លើមប្រភេទ B ត្រូវបានវិនិច្ឆ័យរោគ ដោយការពិនិត្យមួយ នៅក្នុងមន្ទីរពិសោធន៍ ។ ការពិនិត្យពិសេស អាចចង្អុលបង្ហាញថា កើតជម្ងឺតែរយៈពេលខ្លី ឬក៏រ៉ាំរ៉ៃ ។

**តើរោគថ្លើមប្រភេទ B ត្រូវបានព្យាបាលយ៉ាងដូចម្ដេច?**

គ្មានវិធីព្យាបាលរោគថ្លើមប្រភេទ B ឱ្យជានោះទេ ។ ថ្នាំពេទ្យមួយចំនួនត្រូវបានឱ្យអាជ្ញាប័ណ្ណ សម្រាប់ការព្យាបាលរោគថ្លើមប្រភេទ B ប៉ុន្តែអ្នកខ្លះមិនអាចប្រើថ្នាំនេះបានទេ ។

**តើអាចបង្ការរោគថ្លើមប្រភេទ B បានយ៉ាងដូចម្ដេច?**

រោគថ្លើមប្រភេទ B អាចបង្ការបាន ដោយ:

- លាងដៃយ៉ាងប្រុងប្រយ័ត្ន
- សម្លាប់មេរោគ និងបោះចោលរបស់ដែលមានមេរោគ ។
- ថ្នាំបង្ការរោគថ្លើមប្រភេទ B មានផ្ដល់ជូនឱ្យ ហើយជាផ្នែកដ៏ធម្មតាមួយ នៃរបបចាក់ថ្នាំបង្ការពីវ័យក្មេង ។ អ្នករួមផ្ទះទាំងអស់របស់អ្នកមានរោគថ្លើមប្រភេទ B រ៉ាំរ៉ៃ គួរតែចាក់ថ្នាំបង្ការ ។
- ទារកកើតពីម្ដាយមានរោគថ្លើមប្រភេទ B គួរតែចាក់ថ្នាំអ៊ិមយូន ក្លូប៊្យូលិនរោគថ្លើមប្រភេទ B (HBIG) ហើយនិងថ្នាំបង្ការរោគថ្លើមប្រភេទ B នៅក្នុងរយៈពេល 12 ម៉ោង ក្រោយពីសម្រាលកូន ។
- ចៀសវាងការរួមរ័កដោយមិនការពារខ្លួន ជាមួយអ្នកមានរោគថ្លើមប្រភេទ B ។

**សម្រាប់ព័ត៌មានបន្ថែមអំពីរោគថ្លើមប្រភេទ B:**

Ottawa County Health Department
www.miOttawa.org
Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/000279.htm

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វិបសាយ: www.miOttawa.org